# ឆ្នាំទី៣នៃសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន៖ តើសង្គ្រាមនេះនឹងចប់ពេលណា?

អត្ថបទដោយ៖ លោក **ធន ឆាយពិសិដ្ឋ**
អនុប្រធានពិសិដ្ឋអនុប្រធាននាយកដ្ឋាននយោបាយនិងច្បាប់អន្តរជាតិ,
វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា,
រាជបណ្ឌិត្យសភាកម្ពុជា



គិតមកដល់មកដល់ពេលនេះ សង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែនបានចូលឆ្នាំទីបីដោយគ្មានតម្រុយពីការបញ្ចប់សង្គ្រាម ដែលបង្កនូវមហន្តរាយដ៏ធំធេងមិនចំពោះតែប្រទេសទាំងពីរផ្ទាល់ គឺចំពោះពិភពលោកទាំងមូលតែម្តងនេះទេ។ សង្គ្រាមនេះបានបង្កឱ្យមានវិបត្តិមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ ដោយមនុស្សរាប់លាននាក់ត្រូវភៀសខ្លួនចេញពីផ្ទះសម្បែង។ វាក៏បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចពិភពលោក ដែលបណ្តាលឱ្យតម្លៃថាមពល ស្បៀង ចំណីសត្វ កើនឡើង និងរំខានដល់ប្រវាក់ផ្គត់ផ្គង់ពិភពលោកជាខ្លាំង។

ជាប្រវត្តិសាស្ត្រប្រទេសទាំងពីរ អ៊ុយក្រែនធ្លាប់ជាផ្នែកមួយនៃសហភាពសូវៀត ដែលរុស្ស៊ីជាក្បាលម៉ាស៊ីន ដោយហេតុនេះ ចង់មិនចង់ គេមើលឃើញថា រុស្ស៊ីនៅតែចាត់ទុកអ៊ុយក្រែនជាផ្នែកនៃឥទ្ធិពលរបស់ខ្លួន។ បើទោះជារុស្ស៊ី ព្យាយាមរក្សាអ៊ុយក្រែនឱ្យស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួនក៏ដោយ ប៉ុន្តែអ៊ុយក្រែន បែរជាបាននិងកំពុងឆ្ពោះទៅរកទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយលោកខាងលិចទៅវិញ ទាំងការសុំចូលជាសមាជិកសហភាពអឺរ៉ុប ជាពិសេសការសុំចូលបក្សសម្ព័ន្ធយោធាណាតូនេះឯងហើយ គឺជាប្រភពនៃភាពតានតឹងរវាងអ៊ុយក្រែនជាមួយរុស្ស៊ីឈានដល់ដំណាក់កាលទំុដោរ។

យើងឃើញថា ភាពតានតឹងរវាងរុស្ស៊ីនិងអ៊ុយក្រែន បានផ្ទុះឡើងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយក៏បានឈានដល់កម្រិតកំពូលនៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ ពេលរុស្ស៊ីចូលឈ្លានពានចូលអ៊ុយក្រែនឬធ្វើប្រតិបត្តិការយោធាពិសេស តាមការហៅរបស់រុស្ស៊ី។ ការលុកលុយឬប្រតិបត្តិការយោធាពិសេស មកដល់ពេលនេះចូលដល់ឆ្នាំ ទី៣ហើយ តែឆន្ទៈរុស្ស៊ីក្នុងការប្រើប្រាស់កម្លាំងយោធា ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន ដែលរុស្ស៊ីអះអាងថាជាការពារខ្លួនពីភ័យគំរាមកំហែងរបស់បស្ចិមប្រទេស ជាពិសេស ការពង្រីកខ្លួនរបស់អង្គការសម្ព័ន្ធយោធាណាតូ មកអឺរ៉ុបខាងកើត ដែលជាបណ្តាប្រទេសអតីតសហភាពសូវៀត នៅតែរក្សាជំហរដដែល ជាសញ្ញាបង្ហាញឱ្យឃើញថាសង្គ្រាមនេះនឹងអូសបន្លាយយូរបន្តទៅទៀត។ ឯអ៊ុយក្រែនក៏ដូចគ្នា ការទាមទារនៅតែដដែល។

ជាក់ស្តែងប៉ុន្មានខែចុងក្រោយនេះ អ៊ុយក្រែនបានតឿនពិភពលោក ជាពិសេសអឺរ៉ុបនិងសហរដ្ឋអាម៉េរិកពី ការខ្វះអាវុធនិងទ័ព រហូតដល់មានការដកថយកម្លាំងចេញក្រុងអាហ្វឌីកា ក្រោយពីរុស្ស៊ីវាយប្រហារ ដែលចាត់ទុកជាលើកដំបូងដែលរុស្ស៊ីឈ្នះនៅក្នុងសមរភូមិធំចាប់តាំងពីខែឧសភា ឆ្នាំ២០២៣។ អ៊ុយក្រែនបន្តសុំប្រព័ន្ធការពារដែនអាកាសនិងអាវុធច្រើនបន្ថែមទៀត និងសង្កត់ធ្ងន់ថាពេលនេះ ជាអំឡុងពេលសំខាន់ ដោយរុស្ស៊ីកំពុងត្រៀមវាយប្រហារទ្រង់ទ្រាយធំជាថ្មីមកលើខ្លួន។

សូមរំឭកថា កន្លងមកសហរដ្ឋអាម៉េរិកបានផ្តល់ជំនួយដោយផ្ទាល់និងប្រយោលដល់អ៊ុយក្រែនយ៉ាងច្រើន ទាំងហិរញ្ញវត្ថុនិងអាវុធ ប៉ុន្តែបញ្ហាអ៊ុយក្រែនហាក់លែងមានការគាំទ្រពីពលរដ្ឋអាម៉េរិក ដោយគិតថាអាម៉េរិកបានជួយដល់អ៊ុយក្រែនច្រើនពេក ហើយតាមការប៉ាន់ស្មានមួយចំនួនថា បញ្ហានេះក៏អាចក្លាយជាមូលហេតុធ្វើឱ្យប្រជាប្រិយភាពរបស់ចូ បៃដិន និងគណបក្សប្រជាធិបតេយ្យធ្លាក់ចុះផងដែរ។

សង្គ្រាមអូសបន្លាយនាំទៅដល់សំណួរថាតើ សហភាពអឺរ៉ុបដែលមានព្រំដែនជាប់ប្រទេសទាំងពីរនេះ និងក្រុមប្រទេសណាតូ នៅតែគាំទ្រហិរញ្ញវត្ថុនិងសព្វាវុធដល់អ៊ុយក្រែនបានយូរប៉ុណ្ណាទៀត ជាពិសេសនៅពេលដែលសង្គ្រាមនៅមជ្ឈឹមបូព៌ាក៏កំពុងផ្ទុះឡើងនិងមិនបង្ហាញពីតម្រុយបញ្ឈប់ក្នុងពេលឆាប់ៗដូចគ្នា។

យើងឃើញថា ចាប់តាំងពីសង្គ្រាមផ្ទុះឡើង សហភាពអឺរ៉ុបបានប្រមូលផ្តុំធនធានជួយដល់អ៊ុយក្រែន បើគិតទៅលើសពីមួយសែនលានដុល្លារអាម៉េរិកហើយគិតមកដល់ពេលនេះ រីឯចក្រភពអង់គ្លេសបានផ្តល់ជំនួយមិនតិចជាង ១៥ ០០០លានដុល្លារអាម៉េរិកទេ គិតចាប់ពីឆ្នាំ២០២២មក ដោយឡែកអាម៉េរិក បានផ្តល់ជំនួយគិតជារួមជាង ១១៣ ០០០លានដុល្លារអាម៉េរិក។

ចង់មិនចង់ សង្គ្រាមដែលអូសបន្លាយធ្វើឱ្យបណ្តាប្រទេសដែលផ្តល់ជំនួយដល់អ៊ុយក្រែន ត្រូវចំណាយថវិការបស់ខ្លួនជាបន្តបន្ទាប់ ទន្ទឹមនឹងស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសអឺរ៉ុបផ្ទាល់ក៏កំពុងរងឱនភាពយ៉ាងខ្លាំងក្លា ហើយបញ្ហាអតិផរណាក៏កំពុងដាក់សម្ពាធលើជីវភាពប្រជាជនរបស់បណ្តាប្រទេសទាំងនោះឥតឈប់ឈរ ជាហេតុនាំឱ្យមានការរំពឹងថា នឹងនាំមានការសោយចិត្តនិងមិនចង់ឱ្យរដ្ឋាភិបាលរបស់ខ្លួនលូកដៃចូលទៅក្នុងសង្គ្រាមអូសបន្លាយមួយនេះតទៅទៀត។ ទោះយ៉ាងណាកាលពីដើមខែកុម្ភៈនេះ សហភាពអឺរ៉ុបបានយល់ស្របផ្តល់ជំនួយបន្ថែមដល់អ៊ុយក្រែនក្នុងទឹកប្រាក់ ៥៤ ០០០លានដុល្លារអាម៉េរិក រហូតដល់ឆ្នាំ២០២៧។ ការផ្តល់ជំនួយថវិកាដែលមានចំនួនដ៏ច្រើនលើសលុប អាចក្លាយទៅជាបញ្ហានយោបាយរបស់រដ្ឋាភិបាលនីមួយៗ ទន្ទឹមនោះក៏ត្រូវបំបែរចំណាប់អារម្មណ៍មួយភាគធំទៅលើបញ្ហានៅមជ្ឈឹមបូព៌ា ហើយម្យ៉ាងនៅអំឡុងខែមិថុនាខាងមុខក៏មានការបោះឆ្នោតសភាអឺរ៉ុប ដែលគេរំពឹងថាវានឹងជាបញ្ហាខាងនយោបាយដ៏សំខាន់មួយក្នុងតំបន់ផងដែរ។

បញ្ហាដ៏ធំមួយទៀតគឺ លទ្ធភាពជំនួយពីសហរដ្ឋអាម៉េរិកអាចនឹងប្រឈមការប្រែប្រួល ប្រសិនបើគណបក្សប្រជាធិបតេយ្យចាញ់ឆ្នោត ដូច្នេះ ដើម្បីឈ្នះសង្គ្រាម តើអឺរ៉ុបអាចផ្គត់ផ្គង់អាវុធដល់រដ្ឋាភិបាលអ៊ុយក្រែនដោយមិនចាំ

បាច់ពឹងផ្អែកលើជំនួយពីសហរដ្ឋអាមេរិកបានដែរឬទេ។ ប៉ុន្តែ អឺរ៉ុបខ្លួនឯង មិនមានរោងចក្រផលិតអាវុធឯករាជ្យ ដើម្បីផ្គត់ផ្គង់អ៊ុយក្រែននោះទេ។

ចូលដល់ឆ្នាំទីបី សង្គ្រាមអូសបន្លាយដោយមិនមានតម្រុយពីការបញ្ចប់សោះឡើយ ទាំងរុស្ស៊ី អ៊ុយក្រែន និងសម្ព័ន្ធមិត្រអឺរ៉ុបនិងអាម៉េរិក ហាក់គ្មានជំហរបញ្ចប់សង្គ្រាមដោយការចរចាសោះ ដោយភាគីនីមួយៗព្យាយាម អះអាងពីភាពត្រឹមត្រូវរៀងៗខ្លួនក្នុងការប្រើកម្លាំង។ មកដល់ពេលនេះ បើតាមសម្ដីរបស់លោកហ្សេលែនស្គី ទាហាន របស់អ៊ុយក្រែនបានស្លាប់ចំនួន ៣១ ០០០នាក់  ហើយទាហានរុស្ស៊ីស្លាប់ ១៨០ ០០០នាក់ និងរបួស ៥០០ ០០០នាក់ និងតាមអង្គការអន្តរជាតិសម្រាប់ការធ្វើចំណាកស្រុក (IOM) បាននិយាយថា ចាប់តាំងពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ មនុស្សចំនួន១០ ៥៨២នាក់នៅក្នុងប្រទេសអ៊ុយក្រែនបានស្លាប់, ១៩ ៨៧៥នាក់ បានរង របួស, ១៤លាននាក់ត្រូវបានផ្លាស់ទីលំនៅ និងមនុស្សចំនួន៦,៥លាននាក់ បានស្វែងរកការភៀសខ្លួននៅខាង ក្រៅប្រទេស។

សង្គ្រាមនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចពិភពលោក។ វាធ្វើឱ្យតម្លៃថាមពលកើនឡើង និងរំខាន ដល់ច្រវាក់ផ្គត់ផ្គង់ ដែលនាំឱ្យតម្លៃទំនិញនិងសេវាកម្មឡើងថ្លៃ ទន្ទឹមនោះវាក៏បានធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីសន្តិសុខរបស់ប្រទេសផ្សេងៗទៀតទាំងនៅក្នុងតំបន់ ក៏ដូចជាពិភពលោកទាំងមូល ពោលជា វិបត្តិភូមិសាស្ត្រ នយោបាយដ៏ធំមួយដែលនឹងមានផលវិបាករយៈពេលវែង។ ទន្ទឹមនឹងនោះ មកដល់ពេលនេះ មិនទាន់មាននរណា ម្នាក់អាចឆ្លើយទៅនឹងសំណួរថា “តើសង្គ្រាមនេះនឹងចប់ពេលណា?” នៅឡើយទេ បើសហរដ្ឋអាម៉េរិកនិងណាតូនៅ តែប្រើប្រាស់យុទ្ធសាស្ត្រសង្គ្រាមខ្ចីដៃ (Proxy war) នៅអ៊ុយក្រែនទល់នឹងរុស្ស៊ី។ សង្គ្រាមអាចចប់ បើពួកមហា អំណាចចង់បញ្ចប់វា៕

